សមាគមធនាគារនៅកម្ពុជា
THE ASSOCIATION OF BANKS IN CAMBODIA

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

# សេចក្តីថ្លែងការណ៍រួម
# រវាង
# សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ កិច្ចប្រជុំមួយត្រូវបានធ្វើឡើងរវាងគណៈគ្រប់គ្រងរបស់ធនាគារជាតិនៃ កម្ពុជា ហើយនិងគណៈគ្រប់គ្រងរបស់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ។ កិច្ចប្រជុំនេះផ្តោតលើការព្រួយបារម្ភពីការវិវឌ្ឍនៃឧស្សាហកម្មស្រូវនាពេលថ្មីៗនេះ។ យើងខ្ញុំជឿជាក់ថា មានដំណោះស្រាយមួយចំនួនដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចធ្វើបាន ដើម្បីបន្តនិងពង្រីកការជួយគាំទ្រស្ថាប័នពាក់ព័ន្ធនឹងវិស័យកសិកម្ម ។ កិច្ចប្រជុំនេះបានឯកភាពលើចំណុចមួយចំនួនដូចតទៅ ៖

១. បើយោងតាមសហព័ន្ធស្រូវ-អង្ករកម្ពុជា តម្លៃស្រូវនៅកម្ពុជាហាក់បីដូចជាធ្លាក់ចុះ និងធ្វើឲ្យមាននូវការព្រួយបារម្ភពីសុខមាលភាពរបស់ប្រជាកសិករ និងចីរភាពនៃវិស័យស្រូវ-អង្ករ ។ យើងខ្ញុំជឿថា នេះគឺជាបញ្ហាក្នុងតំបន់ដែល បណ្តាលមកពីកត្តាអាកាសធាតុមិនអំណោយផល និងការប្រកួតប្រជែងដ៏ស្រួចស្រាល់នៅក្នុងឧស្សាហកម្មស្រូវ-អង្ករក្នុងតំបន់ ។

២. សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សូមកោតសរសើរដល់ក្រសួង-ស្ថាប័ននានាដែលបានបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្ម ក្នុងការដោះស្រាយបញ្ហាប្រឈមជាប្រព័ន្ធនៅក្នុងវិស័យស្រូវ-អង្ករ ជាពិសេសក្រសួងពាណិជ្ជកម្មដែលបានខិតខំប្រឹងប្រែងស្វែងរកទីផ្សារថ្មីៗ និងបង្កើនកូតាសម្រាប់ស្រូវ-អង្ករកម្ពុជា និងអគ្គិសនីកម្ពុជា ដែលមានជំហរទន់ភ្លន់ចំពោះតម្លៃអគ្គិសនីសម្រាប់រោងម៉ាស៊ីនកិនស្រូវ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀតក្នុងការជាវ និងកំណត់តម្លៃស្រូវកម្ពុជា ។

៣. ទោះបីជាធនាគារត្រូវអនុវត្តការផ្តល់កម្ចីដោយប្រុងប្រយ័ត្ន ដែលចាំបាច់ដើម្បីរក្សាស្ថិរភាព ហើយនិងភាពរឹងមាំរបស់វិស័យហិរញ្ញវត្ថុ យើងខ្ញុំជឿជាក់ថាការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម គឺពិតជាមានសារៈសំខាន់ដូចគ្នាចំពោះសេដ្ឋកិច្ច និងប្រជាពលរដ្ឋកម្ពុជា ព្រោះថាប្រជាពលរដ្ឋភាគច្រើនរស់នៅតំបន់ជនបទ និងមានជីវភាពពឹងផ្អែកលើការប្រមូលផលកសិកម្ម ។ រាជរដ្ឋាភិបាលកម្ពុជា និងធនាគារជាតិនៃកម្ពុជា បានលើកទឹកចិត្តវិស័យហិរញ្ញវត្ថុក្នុងការគាំទ្រយ៉ាងសកម្មលើវិស័យកសិកម្ម តាមរយៈការផ្តល់កម្ចីទៅគ្រប់ខ្សែសង្វាក់ផលិតកម្មស្រូវ ចាប់ពីកសិករ ម្ចាស់រោងចក្រម៉ាស៊ីនកិនស្រូវ និងពាណិជ្ជករទិញ-លក់ស្រូវ ។ ឥណទានលើវិស័យកសិកម្មមានប្រមាណ ២,៨៦០ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង ១៥% នៃឥណទានសរុប ។ ការផ្តល់ឥណទានចំពោះវិស័យកសិកម្ម អាចផ្អែកលើស្ថានភាពហិរញ្ញវត្ថុ លំហូរសាច់ប្រាក់ ការរំពឹងលើការទទួលបានការទូទាត់ ប្រវត្តិនៃការទូទាត់ និងប្រវត្តិឥណទានតាមរយៈព័ត៌មានរបស់

ការិយាល័យឥណទានកម្ពុជា (ក្រេឌីត ប្យូរ៉ូ ខេមបូឌា) អាស្រ័យតាមជំនាញផ្សេងៗគ្នារបស់គ្រឹះស្ថាននីមួយៗ ដោយមិនផ្អែកទាំងស្រុងតែទៅលើការដាក់ទ្រព្យបញ្ចាំនោះទេ។ សមាជិករបស់សមាគម ជឿជាក់ថាហិរញ្ញប្បទានសម្រាប់រោងម៉ាស៊ីនកិនស្រូវ ជាលទ្ធផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ប្រជាកសិករខ្មែរយើង ។

៤. សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សូមកោតសរសើរដល់ស្មារតីបុរេសកម្មនិងភាពជាអ្នកដឹកនាំដ៏រហ័សរហួនរបស់ធនាគារជាតិនៃកម្ពុជា ជាក់ស្តែងតាមរយៈការដាក់ឲ្យអនុវត្តវិធានការណ៍មួយចំនួន ដើម្បីពង្រឹងមូលដ្ឋានទុនរបស់វិស័យធនាគារ និងរក្សានូវសន្ទនីយភាពហិរញ្ញវត្ថុគ្រប់គ្រាន់ ។ ការត្រួតពិនិត្យ និងពង្រឹងការប្រុងប្រយ័ត្នពីធនាគារជាតិនៃកម្ពុជានឹងធានាថាវិស័យធនាគារនៅតែរឹងមាំ និងអាចបន្តផ្តល់ទុនសម្រាប់ទ្រទ្រង់ដល់សេដ្ឋកិច្ច ។

៥. ទោះបីជាបរិបទនៃវិស័យកសិកម្មមានការប្រែប្រួលខ្លាំងយ៉ាងណាក៏ដោយ ក៏វិស័យហិរញ្ញវត្ថុនឹងនៅតែបន្តផ្តល់ការកសាងសមត្ថភាពដល់សមាជិកសហគមន៍ស្រូវ-អង្ករ ក្នុងការពង្រឹងការគ្រប់គ្រងលំហូរសាច់ប្រាក់ និងអាចមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានហិរញ្ញប្បទាន ។ ចំពោះប្រជាកសិករវិញ សមាជិកនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា មានឆន្ទៈគោរពតាមគោលការណ៍ការពារអតិថិជនរបស់ (Smart Campaign) ដូចជា ការផ្តល់នូវផលិតផលសមស្រប ការការពារបំណុលវណ្ឌែក ជម្រុញតម្លាភាព ការកំណត់អត្រាការប្រាក់សមស្រប សមភាព ការគោរពអតិថិជន ការរក្សាការសម្ងាត់ព័ត៌មានអតិថិជន និងយន្តការក្នុងការដោះស្រាយការតវ៉ា ។

៦. ក្នុងស្ថានភាពដ៏លំបាកនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នឹងបន្តផ្តល់កម្ចីដល់រោងម៉ាស៊ីនកិនស្រូវ និងពាណិជ្ជករទិញ-លក់ស្រូវ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានឥណទាន និងគាំទ្រដល់អាជីវកម្មរបស់ពួកគាត់ ។ យើងខ្ញុំ នឹងបន្តតាមដានឥណទានចំពោះវិស័យកសិកម្មឲ្យបានហ្មត់ចត់ និងផ្តល់ការគាំទ្រចាំបាច់ ។ យើងខ្ញុំជឿជាក់ថា ភាពជោគជ័យរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ គឺអាស្រ័យទាំងស្រុងទៅលើជោគជ័យរបស់ អតិថិជនរបស់យើងខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៦